**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តព្រះសីហនុ**

សំណុំរឿងព្រហ្មទណ្ឌលេខ: ១២២១

ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០២០

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ៥២៥/៥៥ (ជ)

ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**

*សាលាដំបូងខេត្តព្រះសីហនុ បានបើកសវនាការជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០២១។*

*ដោយមានសមាសភាព:*

១.លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២.លោក [redacted] ចៅក្រមប្រឹក្សា

៣.លោក [redacted] ចៅក្រមប្រឹក្សា

៤.លោក [redacted] តំណាងអយ្យការ

៥.លោក [redacted] ក្រឡាបញ្ជីសវនាការ

*<u>ដើម្បីជំនុំជម្រះលើជនជាប់ចោទ:</u>*

១.ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ភេទប្រុស អាយុ ២៩ ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ មានទីកន្លែងកំណើតនៅភូមិ០១ ឃុំស្មាច់ដែង ស្រុកជងទង់ ខេត្តកោះកុង និងទីលំនៅបច្ចុប្បន្ន [redacted] ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០១ នាក់,ឪពុកឈ្មោះ [redacted] (រ) , ម្ដាយឈ្មោះ [redacted] (រ) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។ *(ឃុំខ្លួននៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០)*

ត្រូវចោទពីបទ: ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៦ ចំណុច៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ។

២.ឈ្មោះ [redacted] កាម៉ាល់ ភេទប្រុស អាយុ ៣០ ឆ្នាំ ជាតិខ្មែរ ជាតិខ្មែរ-ឥស្លាម មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅសង្កាត់ប្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងទីលំនៅបច្ចុប្បន្ន [redacted] ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ,ឪពុកឈ្មោះ [redacted] (រ) ,ម្ដាយឈ្មោះ [redacted] (រ) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។ *(ឃុំខ្លួននៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០)*

Scanned with CamScanner

ត្រូវចោទពីបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ។

៣.ឈ្មោះ [redacted] ហូសានី ភេទប្រុស អាយុ ៣០ ឆ្នាំ ជាតិខ្មែរ ជាតិខ្មែរ-ឥស្លាម មុខរបរកសិករ មានទីកន្លែងកំណើតនៅក្រុម៧ ភូមិអូរត្រាវ ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងទី[redacted] អណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ,ឪពុកឈ្មោះ[redacted](រ) ,ម្តាយឈ្មោះ[redacted] (រ) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។ *(ឃុំខ្លួននៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០)*

៤.ឈ្មោះ[redacted]លី ភេទប្រុស អាយុ ៣០ ឆ្នាំ ជាតិខ្មែរ ជាតិខ្មែរ-ឥស្លាម មុខរបរកម្មកររោងចក្រ មានទីកន្លែងកំណើតនៅភូមិអូរត្រាវ ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងទីលំនៅបច្ចុប[redacted] ព្រៃនប់ ខេត្តព្រះសីហនុ ,ឪពុកឈ្មោះ [redacted] (រ) ,ម្តាយឈ្មោះ [redacted] (រ) ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន។ *(ឃុំខ្លួននៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០)*

ត្រូវចោទពីបទៈ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុចទី៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

ដោយមានលោក [redacted]រដ្ឋា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅៈ**

កាលពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ វេលាម៉ោង ១៥ និង ២៧ នាទី កម្លាំងសមត្ថកិច្ចជំនាញសហការជាមួយកម្លាំងមូលដ្ឋានស្រុកព្រៃនប់ បានចុះឆែកឆេររកឃើញមានគ្រឿងញៀន ប្រភេទម្សៅសថ្លាចំនួនមួយកញ្ចប់ទម្ងន់ ០,៣៨ ក្រាម ក្រោយពីធ្វើការសាកសួរកម្លាំងសមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ[redacted]ច័ន្ទរ៉ាយ៉ុន ដោយឃាត់បានគ្រឿងញៀនចំនួន ៩៥,៤៦ ក្រាម ដោយមានការទំនាក់ទំនងជាមួយនឹងឈ្មោះ[redacted]និងឈ្មោះ ហ៊ា ក្ ដែលជាអ្នកលក់គ្រឿងញៀននៅរាជធានីភ្នំពេញ។ បន្ទាប់មកកម្លាំងសមត្ថកិច្ចបានឈានទៅរកការឃាត់ឈ្មោះ [redacted] ហូសានី និងឈ្មោះ [redacted]លី ដោយមានការជាប់ពាក់ព័ន្ធនឹងការសមគំនិតក្នុងការលក់គ្រឿងញៀន ។ក្រោយមកទើបកម្លាំងសមត្ថកិច្ចបានកសាងសំណុំរឿងដើម្បីចំណាត់ការតាមច្បាប់ ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ២១៤/២០ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ។

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខៈ ១៤៣៥/២១ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ ។

Scanned with CamScanner

បានឃើញ ដីកាសម្រេចលេខៈ ១៨៥៦/២១ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០២១ ស្តីពីការកំណត់កាលបរិច្ឆេទជំនុំជម្រះរបស់ប្រធានសាលាដំបូងខេត្តព្រះសីហនុ ។

## នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន បានឆ្លើយថាៈ កាលពីថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ វេលាម៉ោង ០៤ រសៀល ខ្លួនបានទិញគ្រឿងញៀនពីឈ្មោះ ជុំក ដោយបានទំនាក់ទំនងពីឈ្មោះ [redacted] ហ្វូសានី ទិញក្នុងតម្លៃ ១.០០០(មួយពាន់) ដុល្លាអាមេរិក ក្នុងនោះខ្លួនបានផ្ញើតាមវីងចំនួន ៨០០(ប្រាំបីរយ) ដុល្លា នៅសល់ចំនួន ២០០(ពីររយ) ដុល្លាទៀត ខ្លួននឹងឲ្យទៅឈ្មោះ [redacted] ហ្វូសានី ពេលខ្លួនបានទទួលគ្រឿងញៀន ។ ចំណែកឈ្មោះ [redacted] កាម៉ាល់ ខ្លួនមានទំនាក់ទំនងដោយធ្លាប់ទិញគ្រឿងញៀន ហើយខ្លួនក៏បែងចែកជាបីកញ្ចប់ ក្នុងមួយកញ្ចប់លក់បានចំនួន ៥០០(ប្រាំរយ) ដុល្លា ។ពេលសមត្ថកិច្ចឃាត់ខ្លួនបានហើយ ខ្លួនក៏ប្រាប់សមត្ថកិច្ចឲ្យទៅឃាត់ខ្លួនឈ្មោះ [redacted] ហ្វូសានី ឈ្មោះ [redacted] កាម៉ាល់ ឈ្មោះ [redacted] លី ដែលជាបក្ខពួករបស់ខ្លួន ។

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] កាម៉ាល់ បានឆ្លើយថាៈ កាលពីថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០ ខ្លួនត្រូវបានសមត្ថកិច្ចបានឃាត់ខ្លួននៅក្នុងសំណាក់ដោយដកហូតបានគ្រឿងញៀនមួយកញ្ចប់ស្មើនឹង ៤៨ (សែសិបប្រាំបី)លេខ ដោយខ្លួនបានទិញមកពីភ្នំពេញសម្រាប់ប្រើប្រាស់ ចំពោះឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ខ្លួនស្គាល់យូរហើយ ហើយឈ្មោះនេះបានឲ្យខ្លួនយកគ្រឿងញៀនពីគេនៅភ្នំពេញ ដោយខ្លួនទទួលបានកម្រៃចំនួន ១០០(មួយរយ) ដុល្លា និងថ្លៃឈ្នួលរថយន្តចំនួន ១០០.០០០(មួយរយពាន់) រៀល ។

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] ហ្វូសានី បានឆ្លើយថាៈ កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០២០ ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន បានទូរស័ព្ទហៅឲ្យខ្លួនមកផ្ទះរបស់គេ ពេលនោះខ្លួនបានពឹងឲ្យឈ្មោះ [redacted] លី ជូនខ្លួនឲ្យមកជាមួយដែរ ពេលមកដល់ខ្លួនក៏ឲ្យយកគណនីហ្វេសប៊ុកអ្នកលក់គ្រឿងញៀននៅភ្នំពេញ ឲ្យឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ទំនាក់ទំនងទិញគ្រឿងញៀនដោយខ្លួនឯង ប៉ុន្តែក្នុងរឿងនេះខ្លួនពុំបានសន្យាទទួលកម្រៃអ្វីមួយពីឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន នោះឡើយ ។

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] លី បានឆ្លើយថាៈ កាលពីថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ ខ្លួនបានជូនឈ្មោះ [redacted] ហ្វូសានី ទៅផ្ទះរបស់ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន តាមការពឹងពាក់ ខ្លួនពុំដែលយកគ្រឿងញៀនឲ្យគេដែរ ពេលនោះខ្លួនបានឃើញឡានមួយគ្រឿងចតនៅមុខផ្ទះរបស់ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ប៉ុន្តែខ្លួនពុំបាននិយាយអ្វីឡើយ ។ខ្លួនដឹងថាឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ជាអ្នកជួញដូរគ្រឿងញៀន ហើយគាត់តែងតែឲ្យគ្រឿងញៀនមកខ្លួនសម្រាប់ប្រើប្រាស់ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថាៈ នៅក្នុងសវនាការឈ្មោះ ប៊ិន ច័ន្ទរ៉ាយ៉ុន បានសារភាពថាខ្លួនបានទិញគ្រឿងញៀន ដោយផ្ញើតាមរយៈឡានវីរៈប៊ុនថាំ សម្រាប់ធ្វើការលក់បន្ត ស៊ីសង្វាក់គ្នាជាមួយនឹងវត្ថុតាងគ្រឿងញៀនដែលដកហូតបានមានទម្ងន់ ៩៥,៩៦ ក្រាម រួមជាមួយនឹងការប្រើប្រាស់គ្រឿងញៀនផងដែរ ដែលអំពើនេះជាការជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ០៦ ចំណុច០៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ចំពោះឈ្មោះ [redacted] កាម៉ាល់ ពេលសមត្ថកិច្ចឃាត់ខ្លួនដក



Scanned with CamScanner

ហ្វូតបានគ្រឿងញៀនមួយកញ្ចប់ស្មើនឹង ០,៣៨ ក្រាម ជាមួយនឹងការប្រើប្រាស់គ្រឿងញៀន ដែលការប្រព្រឹត្តនេះជាអំពើរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ និង មាត្រា ៩៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំណែកឈ្មោះ [redacted] ហ្វូសានី និងឈ្មោះ [redacted] លី បានបដិសេធនូវទង្វើរបស់ខ្លួន ប៉ុន្តែសកម្មភាពរបស់ជនជាប់ចោទទាំងពីរ ស្តែងឡើងក្រោមរូបភាពសម្រួលដល់ការជួញដូរគ្រឿងញៀនរបស់ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន និងការប្រើប្រាស់គ្រឿងញៀន ដែលអំពើនេះជាការសមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ មាត្រា ៤០ កថាខណ្ឌទី ០៦ ចំណុច៤ និងមាត្រា ៩៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មេធាវីបានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោលកូនក្តីខ្លួនទាំងបីមានឈ្មោះ [redacted] ហ្វូសានី ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន និងឈ្មោះ [redacted] កាម៉ាល់ បានទទួលសារភាពពីកំហុសរបស់ខ្លួនហើយ នៅក្នុងរឿងនេះខ្លួនសូមឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ចំណែកឈ្មោះ [redacted] លី ពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយការឆ្លើយបញ្ជាក់ពីមានភស្តុតាង និងអង្គហេតុមិនច្បាស់លាស់ នៅមានវិមតិសង្ស័យ ដូច្នេះសូមឲ្យតុលាការពិចារណាឲ្យឈ្មោះ [redacted] លី រួចផុតពីបទចោទប្រកាន់ ។

-ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន បានសំណូមពរជាចុងក្រោយថា: សូមឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសមកលើរូបខ្លួនដោយក្តីអនុគ្រោះ ។

-ជនជាប់ចោទឈ្មោះ [redacted] ហ្វូសានី បានសំណូមពរជាចុងក្រោយថា: សូមឲ្យតុលាការមេត្តាជួយសម្រួលពិនិត្យសើរើរឿងឡើងវិញ ។

-ជនជាប់ចោទឈ្មោះ [redacted] កាម៉ាល់ បានសំណូមពរជាចុងក្រោយថា: សូមឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសមកលើរូបខ្លួនដោយក្តីអនុគ្រោះ ។

-ជនជាប់ចោទឈ្មោះ [redacted] លី បានសំណូមពរជាចុងក្រោយថា: សូមឲ្យតុលាការមេត្តាជួយលើកលែងទោសមកលើរូបខ្លួនដោយក្តីអនុគ្រោះ ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ

ក្រោយពីបានពិនិត្យ ភស្តុតាង ឯកសារទាំងអស់ក្នុងសំណុំរឿង

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាដំបូងខេត្តព្រះសីហនុយល់ឃើញថា៖

១-តុលាការបានទទួលបណ្តឹងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ១៤៣៥/២១ ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០២១ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តព្រះសីហនុ ដែលបានបញ្ជូនជនជាប់ចោទ: ១. ឈ្មោះ [illegible]



Scanned with CamScanner

យ៉ុន ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៦ ចំណុច៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ២.ឈ្មោះ [redacted] កាម៉ាល់ ពីបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ៣.ឈ្មោះ [redacted] ហូសានី និង ៤.ឈ្មោះ [redacted] លី ពីបទៈ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៦ ចំណុចទី៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

**២**-ចម្លើយជនជាប់ចោទឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ឆ្លើយថាៈ កាលពីថ្ងៃកើតហេតុ ខ្លួនពិតជាបានទិញគ្រឿងញៀន ដោយមានឈ្មោះ [redacted] ហូសានី ជាអ្នកជួយឲ្យគណនីហ្វេសប៊ុកអ្នកលក់ឲ្យ ហើយខ្លួនក៏សន្យាថាឲ្យប្រាក់ទៅឈ្មោះ [redacted] ហូសានី ចំនួន ២០០(ពីររយ) ដុល្លា ពេលយកគ្រឿងញៀនបាន ចំណែកឈ្មោះ [redacted] កាម៉ាល់ ខ្លួនក៏ធ្លាប់មានទំនាក់ទំនងទិញគ្រឿងញៀនផងដែរ ចំណែកឈ្មោះ [redacted] លី ជាបក្ខពួករបស់ខ្លួន ។

**៣**-ចម្លើយជនជាប់ចោទឈ្មោះ [redacted] កាម៉ាល់ ឆ្លើយថាៈ កាលពីថ្ងៃកើតហេតុ សមត្ថកិច្ចបានឃាត់ខ្លួនរួមជាមួយនឹងគ្រឿងញៀនមួយកញ្ចប់ ខ្លួនធ្លាប់យកគ្រឿងញៀនឲ្យឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ហើយបានទទួលកម្រៃចំនួន ១០០ (មួយរយ) ដុល្លា ។

**៤**-ចម្លើយជនជាប់ចោទឈ្មោះ [redacted] ហូសានី ឆ្លើយថាៈ កាលពីថ្ងៃកើតហេតុ ខ្លួនពឹងឲ្យឈ្មោះ [redacted] លី ជូនទៅផ្ទះរបស់ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ហើយខ្លួនក៏យកគណនីហ្វេសប៊ុកអ្នកលក់គ្រឿងញៀនឲ្យឈ្មោះ រ៉ាយ៉ុន ទំនាក់ទំនងទិញដោយខ្លួនឯង ខ្លួនពុំបានទទួលកម្រៃអ្វីទេ ។

**៥**-ចម្លើយជនជាប់ចោទឈ្មោះ [redacted] លី ឆ្លើយថាៈ កាលពីថ្ងៃកើតហេតុ ខ្លួនបានទៅផ្ទះរបស់ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ជាមួយនឹងឈ្មោះ [redacted] ហូសានី ហើយឃើញឡានមួយគ្រឿង ប៉ុន្តែមិនបាននិយាយអ្វីទេ ។ខ្លួនដឹងថាឈ្មោះ ប៊ុន ច័ន្ទរ៉ាយ៉ុន ជាអ្នកជួញដូរគ្រឿងញៀន ហើយគាត់តែងតែឲ្យគ្រឿងញៀនមកខ្លួនសម្រាប់ប្រើប្រាស់ ។

**៦**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថាៈ នៅក្នុងសវនាការឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន បានបានសារភាពថាខ្លួនបានទិញគ្រឿងញៀន ដោយផ្ញើតាមរយៈឡានវីរៈប៊ុនថាំ សម្រាប់ធ្វើការលក់បន្ត ស៊ីសង្វាក់គ្នាជាមួយនឹងវត្ថុតាងគ្រឿងញៀនដែលដកហូតបានមានទម្ងន់ ៩៥,៨៦ ក្រាម រួមជាមួយនឹងការប្រើប្រាស់គ្រឿងញៀនផងដែរ ដែលអំពើនេះជាការជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ០៦ ចំណុច៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ចំពោះឈ្មោះ [redacted] កាម៉ាល់ បើគិតចំនួនសម្រាប់



Scanned with CamScanner

ខ្លួនដកហូតបានគ្រឿងញៀនមួយកញ្ចប់ស្មើនឹង ០,៣៨ ក្រាម ជាមួយនឹងការប្រើប្រាស់គ្រឿងញៀន ដែលការប្រព្រឹត្តនេះជាអំពើរក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ៤០ និង មាត្រា ៩៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ចំណែកឈ្មោះ [redacted] ហូសានី និងឈ្មោះ [redacted] លី បានបដិសេធនូវទង្វើរបស់ខ្លួន ប៉ុន្តែសកម្មភាពរបស់ជនជាប់ចោទទាំងពីរ ស្តែងឡើងក្រោមរូបភាពសម្រួលដល់ការជួញដូរគ្រឿងញៀនរបស់ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន និងការប្រើប្រាស់គ្រឿងញៀន ដែលអំពើនេះជាការសមគំនិត និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមបញ្ញត្តិមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ មាត្រា ៤០ កថាខណ្ឌទី ០៦ ចំណុច៤ និងមាត្រា ៩៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ការប្តឹងសុំរបស់តំណាងអយ្យការ តុលាការអាចពិចារណាបាន ដោយផ្អែកទៅលើធាតុសុទ្ធនៃសារធាតុញៀន បើពិនិត្យមើលតាមអង្គហេតុឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន បានទទួលសារភាពថាខ្លួនបានទិញគ្រឿងញៀននោះមកទុកសម្រាប់លក់បន្ត និងប្រើប្រាស់ ចំណែកឈ្មោះ [redacted] កាម៉ាល់ ពេលសមត្ថកិច្ចឃាត់ខ្លួនជាក់ស្តែងដកហូតបានគ្រឿងញៀន ដោយជនជាប់ចោទទទួលថាពិតជាគ្រឿងញៀនរបស់ខ្លួនទុកសម្រាប់ប្រើប្រាស់ ចំណែកឈ្មោះ [redacted] ហូសានី និងឈ្មោះ [redacted] លី ទោះបីជាខិតខំបដិសេធ ប៉ុន្តែតាមចម្លើយរបស់ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ពិតជាបានបញ្ជាក់ពីសកម្មភាពក្នុងការជួយសម្រួលដល់ ការលក់គ្រឿងញៀន និងបានប្រើប្រាស់គ្រឿងញៀន រួមជាមួយនឹងតេស្តិ៍វិជ្ជមានសារធាតុញៀននៅក្នុងខ្លួន ដែលអំពើរបស់ជនជាប់ចោទទាំងបួន គប្បីតុលាការផ្តន្ទាទោសតាមច្បាប់ ។

៧-មេធាវីបានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងតាមការសួរដេញដោលកូនក្តីខ្លួនទាំងបីមានឈ្មោះ [redacted] ហូសានី ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន និងឈ្មោះ [redacted] កាម៉ាល់ បានទទួលសារភាពពីកំហុសរបស់ខ្លួនហើយ នៅក្នុងរឿងនេះខ្លួនសូមឲ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ចំណែកឈ្មោះ [redacted] លី ពុំបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ដោយការឆ្លើយបញ្ជាក់គ្មានភស្តុតាង និងអង្គហេតុមិនច្បាស់លាស់ នៅមានវិមតិសង្ស័យ ដូច្នេះសូមឲ្យតុលាការពិចារណាឲ្យឈ្មោះ [redacted] លី រួចផុតពីបទចោទប្រកាន់ ។ ការស្នើសុំរបស់មេធាវីតុលាការមិនអាចធ្វើការពិចារណាបានឡើយ តាមការប្រព្រឹត្តរបស់ឈ្មោះ [redacted] លី ជាការជួយសម្រួលដល់ជនជាប់ចោទឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន នៅក្នុងការលក់គ្រឿងញៀន តុលាការបានពិនិត្យឃើញពីការទទួលបានប្រយោជន៍(ការជក់គ្រឿងញៀន) តាមរយៈឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ជាអ្នកឲ្យ ចំណែកជនជាប់ចោទទាំងបី តុលាការក៏មិនអាចពិចារណាលើស្ថានសម្រាលបានដែរ ដោយសារតែអំពើប្រព្រឹត្តនេះមានព្យសនកម្មធ្ងន់ធ្ងរដល់សង្គម ។

៨-តាមការសួរដេញដោលនាអង្គសវនាការ ការស្តាប់ចម្លើយជនជាប់ចោទ សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ សេចក្តីសន្និដ្ឋានរបស់មេធាវី ព្រមទាំងភស្តុតាងនានាក្នុងសំណុំរឿង អាចឲ្យតុលាការជឿបានថារាល់អំពើជនជាប់ចោទឈ្មោះ [redacted] ច័ន្ទរ៉ាយុន ពិតជាបានជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ស្តែងចេញតាមរយៈការទិញយកគ្រឿងញៀន ហើយលក់បន្តទៅវិញក្នុងគោលបំណងប្រាក់ចំណេញ ចំណែកឈ្មោះ [redacted] ហូសានី និងឈ្មោះ [redacted] លី ស្តែងឡើងតាមរយៈការជួយសម្រួលដល់សកម្មភាពរបស់ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ក្នុងការលក់គ្រឿងញៀន និងការប្រើប្រាស់គ្រឿងញៀន ដែលអំពើនេះជាការសមគំនិតក្នុងការជួញដូរ និងប្រើ



Scanned with CamScanner

ប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។ ចំណែកឈ្មោះ [redacted] កាម៉ាល់ ពេលឃាត់ខ្លួនបានគ្រឿងញៀនមួយកញ្ចប់ ដែលជនជាប់ចោទសារភាពថាគ្រឿងញៀននោះទុកសម្រាប់ជក់ ដែលការប្រព្រឹត្តនេះជាការរក្សាទុក និងប្រើប្រាស់គ្រឿងញៀន ។

៩-គ្រឿងញៀនដែលដកហូតបានពីឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន មានចំនួន ៩៥,៤៦ ក្រាម ដែលមានកម្រិតជាតុសុទ្ធ ៧៨,១៣ ភាគរយ ដូច្នេះជាតុសុទ្ធនៃគ្រឿងញៀនមានៈ ៩៥,៤៦ ក្រាម x ៧៨,១៣ /១០០ =៧៤,៥៨ ក្រាម ដែលចំនួននេះ គប្បីតុលាការពិចារណាផ្តន្ទាទោសដោយផ្អែកលើមាត្រា ៤០ កថាខណ្ឌទី ០៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១០-គ្រឿងញៀនដែលដកហូតបានពីឈ្មោះ [redacted] កាម៉ាល់ មានចំនួន ០,៣៨ ក្រាម ដែលមានកម្រិតជាតុសុទ្ធ ៧៨,១៣ ភាគរយ ដូច្នេះជាតុសុទ្ធនៃគ្រឿងញៀនមានៈ ០,៣៨ ក្រាម x ៧៨,១៣ /១០០ =០,២៩ ក្រាម ដែលចំនួននេះ គប្បីតុលាការពិចារណាផ្តន្ទាទោសដោយផ្អែកលើមាត្រា ៤០ កថាខណ្ឌទី ០៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

១១-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទៈ

១១-១ ឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ភេទប្រុស អាយុ ២៩ ឆ្នាំ ។

ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ០៥ ចំណុច៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ។

១១-២ ឈ្មោះ [redacted] ហ្វសានី ភេទប្រុស អាយុ ៣០ ឆ្នាំ ។

១១-៣ ឈ្មោះ [redacted] លី ភេទប្រុស អាយុ ៣០ ឆ្នាំ ។

ពីបទៈ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌ៥ ចំណុចទី៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

១១-៤ ឈ្មោះ [redacted] កាម៉ាល់ ភេទប្រុស អាយុ ៣០ ឆ្នាំ ។

ពីបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ០៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ។

១២-វត្ថុតាងរួមមានៈ



Scanned with CamScanner

**១២-១** គ្រឿងញៀនមេតំហ្វេតាមីន ចំនួន ៩៥,៩៦ ក្រាម ដែលដកហូតចេញពីឈ្មោ [redacted] ច័ន្ទរ៉ាយ៉ុន និងគ្រឿងញៀនមេតំហ្វេតាមីនចំនួន ០,៣៨ ក្រាម ដែលដកហូតពីឈ្មោះ [redacted] ម៉ាល់ ដែកកេះចំនួនមួយ និងខ្សៀជក់ចំនួនមួយ គប្បីតុលាការរឹបអូស និងបំផ្លាញចោល ។

**១២-២** ទូរស័ព្ទចំនួនបួនគ្រឿង(អូប៉ូ១ អាយហ្វូនស៊ិច១ ម៉ី២ ) និងប្រាក់រៀលចំនួន ២៤០.០០០(ម្ភៃបួនម៉ឺន)រៀល គប្បីតុលាការធ្វើការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។

**១៣**-ជនជាប់ចោទជានីតិជន ដែលមានភស្តុតាង ឬសញ្ញាណបញ្ជាក់ថាកើតមានវិបល្លាសស្មារតីដែលបន្ថយនូវ ការដឹងខុសត្រូវរបស់ខ្លួន ជននេះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌលើអំពើប្រព្រឹត្តរបស់ខ្លួន ។

## ហេតុដូច្នេះសម្រេច

**១**-កែប្រែបញ្ញត្តិមាត្រាចំពោះជនជាប់ចោទឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន មាត្រា ៤០ កថាខណ្ឌទី ៦ ចំណុច៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកមាត្រា ៤០ កថាខណ្ឌទី ៥ ចំណុច៦ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ។

**២**-កែប្រែបញ្ញត្តិមាត្រាចំពោះជនជាប់ចោទឈ្មោះ [redacted] ហូសានី និងឈ្មោះ [redacted] លី មាត្រា ៤០ កថាខណ្ឌទី ៦ ចំណុច៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា ពីបទៈ សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន មកមាត្រា ៤០ កថាខណ្ឌទី ៥ ចំណុច៦ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា ។

**៣**-ផ្ដន្ទាទោសជនជាប់ចោទៈ

**៣-១** ឈ្មោ [redacted] ច័ន្ទរ៉ាយ៉ុន ភេទប្រុស អាយុ ២៩ ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៨(ប្រាំបី)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១៥.០០០.០០០(ដប់ប្រាំលាន)រៀល ។

ពីបទៈ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី ៥ ចំណុច៦ និងមាត្រា ៤៥ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ។

**៣-២** ឈ្មោះ [redacted] ហូសានី ភេទប្រុស អាយុ ៣០ ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០០(ដប់លាន)រៀល ។

**៣-៣** ឈ្មោះ [redacted] លី ភេទប្រុស អាយុ ៣០ ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ១០.០០០.០០០០(ដប់លាន)រៀល ។

ពីបទៈ សមគំនិតក្នុងអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០២០ បទ

Scanned with CamScanner

ល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨០ កថាខណ្ឌ៥ ចំណុចទី៦ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា និងមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ ។

៣-៤ ឈ្មោះ [redacted] កាម៉ាល់ ភេទប្រុស អាយុ ៣០ ឆ្នាំ ដាក់ពន្ធនាគារចំនួន ០២(ពីរ) ឆ្នាំ ០៦(ប្រាំមួយ) ខែ។ ពីបទៈ រក្សាទុក និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវាលមាស ឃុំវាលរេញ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែ កញ្ញា ឆ្នាំ ២០២០ និងថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៨០ កថាខណ្ឌទី ០៤ និងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ព្រះរាជាណាចក្រកម្ពុជា ។

៤-វត្ថុតាងរួមមាន:

៤-១ គ្រឿងញៀនមេតំហ្វេតាមីន ចំនួន ៩៥,៤៦ ក្រាម ដែលដកហូតចេញពីឈ្មោះ ប៊ុន ច័ន្ទរ៉ាយ៉ុន និងគ្រឿងញៀនមេតំហ្វេតាមីនចំនួន ០,៣៨ ក្រាម ដែលដកហូតពីឈ្មោះ [redacted] កាម៉ាល់ ដែកកេះចំនួនមួយ និងខ្សៀជក់ចំនួនមួយ តុលាការរឹបអូស និងបំផ្លាញចោល ។

៤-២ ទូរស័ព្ទចំនួនបួនគ្រឿង(អូប៉ូ១ អាយហ្វូនស៊ិច១ ម៉ី២ ) និងប្រាក់រៀលចំនួន ២៤០.០០០(ពីររយសែសិបពាន់)រៀល តុលាការធ្វើការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។

៥-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ច័ន្ទរ៉ាយ៉ុន ឈ្មោះ [redacted] ហូសានី ឈ្មោះ [redacted] លី និងឈ្មោះ [redacted] កាម៉ាល់ ។

ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ ចៅក្រមប្រឹក្សា ចៅក្រមប្រឹក្សា ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted] [redacted] [redacted]

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃទី [illegible] ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

Scanned with CamScanner